ព្រះ
ត្រៃបិដកចារលី
និង
សេចក្តីប្រែជាភាសាខ្មែរ
វិនយបិដក
មហាវិភង្គ បឋមភាគ
១

វេរញ្ជកណ្ឌ និង បារាជិកកណ្ឌ

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

៣ សរ ២៤៩៧

ឯកសារគម្ពីរព្រះត្រៃបិដកស្កានេះ
ត្រូវទាបថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជាទបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ។ និងទុកក្នុង
គេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។

កែសម្រួលតាមកុំព្យូទ័រ តម្រូវឲ្យបកវណ៌អានអេឡិត្រូនិច
ដោយខ្ញុំព្រះករុណាខ្ញុំបាទ ស្រុង-ចាន់ណា ។

www.5000-years.org

ជ្រោះ
ថ្មែជិដកជាម្ចាស់
នឹង
សេចក្តីប្រែជារាសាខ្មែរ
ទុនយជិដក
ជាមហាទុក្ខ បរមទុរាគ
១

វេញ្ចកណ្ឌនឹងជាវជិកុកណ្ឌ

ពោះពុម្ពលើកទី ២



ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

៣ ស ២៤៩៧

ឧទ្ទិសកថា

យើងខ្ញុំ សូមថ្លង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនា
ជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវរន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើយោរយៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះចរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

អ្នកតំណាងចាត់ការ The Rev. Seikyo Muchaku

ប្រធានការិយាល័យ The Rev. Eiitsu Shinohara

អ្នកចាត់ការ

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを怨し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年７月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭　　世話人　松永　然道　　有馬　実成
事務局長　　篠原　鋭一　　　　伊藤　佳通　　渡井　奎一
　　　　杉谷　義純　　茂田　真澄
　　　　前田　利勝　　中島　教之
　　　　永　　六輔

Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

TRIPITAKA PUBLISHING SUPPORT COMMITTEE
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

Les fonds nécessaires à l'édition du premier volume du TRIPITAKA ont été offerts personnellement par Monsieur PAUL REYNAUD, Ministre des Colonies. en témoignage de l'intérêt que le Gouvernement de la République Française porte au Peuple Cambodgien.

Un exemplaire de ce premier volume a été remis le Vingt-Deux Octobre Mil Neuf Cent Trente et Un, en audience solennelle, à SA MAJESTÉ SISOWATH MONIVONG par Monsieur PAUL REYNAUD, assisté de Monsieur le Gouverneur Général PASQUIER et de Monsieur le Résident Supérieur LAVIT, en présence du Conseil des Ministres, des Chefs de Secte et d'une délégation de tous les bonzes du Royaume.

ទ្រាត់ចំណាយ ក្នុងការចោះពុម្ពព្រះត្រៃបិដក
ខ្មែរនេះ គឺលោកប៉ូលវេណ្ហូន សេចក្តីក្រសួង
ប្រទេសកម្ពុជាបានចូល ដើម្បីឲ្យយើញជាភ័ស្តុតាងនៃ
ប្រយោជន៍ដែលការជាជាងបត់ ចាក់ងសែស
ជាំមកឲ្យដល់ខេមរជាតិ ។

សៀវភៅនីនេះ លោកប៉ូលវេណ្ហូន ចាងថ្វាយមួយ
ខ្សែចំពោះព្រះករុណាព្រះចាងសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស
ចមចក្រពង្ស ក្នុងឱកាសដែលចូលគាល់ជាមង្គល
អំពីថ្ងៃថ្លៃពីរតុលា ឆ្នាំមួយពាន់ប្រាំបួនរយសាមសិប
មួយ ជួបជុំជាមួយនឹងលោក ឡឺក្លែរណើរ យេណេ-
កលចាស្តីយោ នឹងលោក ឡឺវេស៊ីដង់ត៍ សុប៉ែរាយើរ
ឧត្តរិត នៅនីចំពោះមុខអស់លោកកុង្ស៊ុយស៊ែចាបត៍
ក្នុងព្រះសង្ឃជាយកចាំងពីរតណា: នឹងតំណាងសង្ឃ
ក្រប់អង្គ ក្នុងស្រុកខ្មែរមួយក្រុម ។

ព្រះរាជពន្ធមាន

ព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ចមចក្រពង្ស ហរិរាជបរមិន្ទរក្សវិណ
វៃក្រែកែវហ្វា សុឡាវៃឡ្ស ព្រះចៅក្រុងកម្ពុជាធិបតី ជាអំម្ចាស់ដីវិតលើត្បូង

ទ្រង់សូមអំណរព្រះតេជព្រះគុណ ជាបឋមហេតុនៅទីនេះ ដែលក្រុងបារាំងសែស ដែលជួយទំនុកបម្រុងក្រុងកម្ពុជា ដោយសុបរិតបានប្តើងរុងរឿងរៀងមកនឹងតទៅមុខ ហើយដោយបានបង្កើតមន្ទីរពុទ្ធសាសនបណ្ឌិត្យ បានយកចិត្តទុកដាក់ជួយទំនុកបម្រុងនឹងធ្វើឲ្យព្រះបារមីព្រះពុទ្ធសាសនា នឹងជួយឲ្យបោះពុម្ព

ព្រះត្រៃបិដកជាខ្លឹមឫសកែវព្រះពុទ្ធសាសនា ជាសេចក្តីរាប់អាន
ពេញចិត្តរបស់បណ្តាខេមរជនទាំងអស់គ្នាឥសល់ ហើយទ្រង់
ពុំមានភ្លេចទ្បើយ បំពោះអំណរអរគុណដល់ពួកឧបាសក
ឧបាសិកាដែលមានចិត្តសទ្ធាជ្រះថ្លា បេញប្រាក់ប្លួសជួយឲ្យ
ការដ៏ឧត្តមនេះបានសម្រេច ។

ទ្រង់មានសេចក្តីសោមនស្សជ្រៅទីបំផុត ដែលក្នុងរវាងដែនដី
ទ្រង់ព្រះករុណាបានសម្រេចឲ្យមានក្រុមជំនុំព្រះសង្ឃបណ្ឌិតប្រៃ
ព្រះបាទ្បីក្នុងគម្ពីរព្រះត្រៃបិដក គឺភាជន:ទាំង ៣ ដែលជំកល់ជាក់
ក្បួនព្រះពុទ្ធសាសនា មានទាំងអស់ប្រាំបីម៉ឺនប្លួនពាន់ព្រះធម្មក្ខន្ធ
មកជាភាសាខេមរ:ជាក់ស្តែង ឲ្យបោះពុម្ពទាំងបាទ្បីធ្វើឯសម្រាយ
ជាសៀវភៅធ្វើយព្រះមធុរសក្នុងព្រះវិន័យ គឺកាន់ក្រិត្យធ្វើឯគំនិត
មារយាទ ។ ព្រះសូត្រគឺព្រះធម៌សំរាប់ប្រដៅសត្វឲ្យកាន់វិធី
ត្រង់ ។ ព្រះអភិធម្ម គឺញ៉ាំងផ្លូវព្រះបរមនិព្វានដែលព្រះពុទ្ធអង្គ
ព្រះសមណគោតមបានត្រាស់ហើយ ទ្រង់សំដែងទុកឲ្យមនុស្ស

លោកកាន់ប្រព្រឹត្តឲ្យត្រឹមត្រូវ ធំឯបានតម្រង់លេតសិករាល់រូបកាយ ឲ្យប្រកបដោយសេចក្តីបរិសុទ្ធិ ជាបំហុតក្នុងការកុសលទើបបង្កើតជាមគ្គផល ដែលអាចធ្វើឲ្យបានសេចក្តីក្សេមក្សាន្ត ធំឯបំពីនសិរីសួស្តីដ៏ប្រពៃប្លែកគួម ជាបរមសុខ ដល់បរិសទ្យទាំងពួងគ្រប់គ្នា ។

ដោយហេតុព្រះធម៌ដ៏វិសេសទាំងនោះសុទ្ធតែជាបាឡីគឺព្រះពុទ្ធវចនៈពីបុរាណតាំងពីមុនព្រះពុទ្ធសករាជ ២៤៧៤ ទៅទៀត បានជាព្រះសង្ឃនឹងឧបាសកប្រើនរៀនបេះចាំបាន តែមិនយល់ច្បាស់ជាដូអ្វី បានជាព្រះករុណាទ្រង់ព្រះរាជតំរិះព្រមនឹងរាជការប្រតិកគ្គរាត់ក្រុងបារាំងសែសមានលោកឡឺវែស៊ីដង់ត៍សុប៉ែរីយើរហ្វែណង់ឡាវិត ជាតំណាង ដែលទ្រង់សួរអំណរគុណដោយរួសរាន់ ក្នុងឱកាសដែលបានជួយគិតសម្រេចមហាប្រយោជន៍ឧត្តមនេះ ឲ្យបានបំពីនតំរិះប្រាជ្ញាជាតិខេមរៈ ឲ្យកាន់តែបេះដឹងមាំមួនឡើង ដើម្បីនឹងរក្សាព្រះពុទ្ធសាសនាឲ្យខ្ជាប់ខ្ជួនជាទី

រុងរឿងនៃក្រុងកម្ពុជា ឥតអាក់ ដោយបានតាំងមន្ទីរពុទ្ធ-
សាសនបណ្ឌិត្យ នឹងព្រះរាជបណ្ណាល័យ ហើយឲ្យបោះពុម្ពគម្ពីរ
ព្រះត្រៃបិដក ទុកជាគោល ដើម្បីឲ្យអស់មហាជនទាំងឡាយ
ដែលកាន់ព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌូចិនទាំងមូល រឹតតែ
ជឿព្រះពុទ្ធសាសនាមហាប្រសើរបែមទៀត ។

ធ្វើក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញ្ញបត្តម្ភ ៦ នៅថ្ងៃព្រហស្បត៍
១៣ រោចខែស្រាពណ៍ ឆ្នាំមមែត្រីស័ក ព្រះពុទ្ធសករាជ ២៤៧៤
ត្រូវនឹងថ្ងៃ ១០ កញ្ញា ឆ្នាំ ១៩៣១ ។

កថាមុខរបស់ក្រុមជំនុំ

អំពីប្រវត្តិហេតុការគាស់ព្រះត្រៃបិដក

ការផ្ទៀងព្រះត្រៃបិដកជាភាសាបាឡី ធំងការប្រែពីបាឡី មកជាសម្រាយភាសាខ្មែរនេះ យើងជាក្រុមជំនុំបានចាប់ផ្តើមធ្វើតាំងពីថ្ងៃ ៣ កើតខែបុស្ស ឆ្នាំមមីទោស័ក ពុទ្ធសករាជ ២៤៧២ ត្រូវនឹងថ្ងៃទី ២ ខែមករា ១៩៣០ នៅមន្ទីរព្រះរាជបណ្ណាល័យ កម្ពុជា ក្រុងភ្នំពេញ ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ ។ ការគាស់ព្រះត្រៃបិដកនេះ កើតឡើងដោយព្រះការុណាព្រះបាទ សម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះចៅក្រុងកម្ពុជា ដែលទ្រង់ព្រះបិន្ទាបង់ឧបត្ថម្ភព្រះពុទ្ធសាសនា ដោយការបោះពុម្ពផ្សាយព្រះត្រៃបិដក ហើយប្រគល់ការបោះពុម្ពនេះ មកឲ្យព្រះរាជបណ្ណាល័យ ។ ការគាស់ព្រះត្រៃបិដកនេះកើតឡើងដោយរាជការប្រុងប្រយ័ត្នធំង ដោយបានបង្កើតពុទ្ធសាសនបណ្ឌិត្យ

ហើយតម្រូវការឲ្យជួយព្រះរាជបណ្ណាល័យ នឹងឲ្យរកបិត្តទុក ដាក់ក្នុងការទាំងឡាយ ដែលមានឧត្តមប្រយោជន៍ដល់ព្រះពុទ្ធសាសនា ។

អំពីសេចក្តីចំរើននៃការបោះពុម្ពព្រះត្រៃបិដក

សេចក្តីចំរើនដែលនាំមុខការបោះពុម្ពព្រះត្រៃបិដកនេះ ឲ្យប្រព្រឹត្តទៅដោយស្រួល គឺមានទើសទាក់នោះ ព្រោះអាស្រ័យប្រាក់បំណុលដូចមានសេចក្តីតទៅនេះ :

១ ដោយព្រះករុណាជាម្ចាស់ជីវិត ព្រះបៀក្រុងកម្ពុជា ទ្រង់បានចំណាយប្រាក់ព្រះរាជទ្រព្យសម្រាប់ព្រះអង្គ ជួយទំនុកបម្រុងក្នុងការបោះពុម្ពនេះ ហើយទ្រង់បានឥតឈ្នួលព្រះរាជវិង្សានុវង្សអស់លោកមន្ត្រីធំតូច នឹងព្រះភិក្ខុសង្ឃ បើរានុត្តេរៈ រាជាគណៈហានានុក្រមឲ្យជួយទំនុកបម្រុងក្នុងការបោះពុម្ពនេះផង ។

២ ដោយព្រះរាជវិង្សានុវង្សនឹងអស់លោកកុងស៊ុយសេនាបតីនួរអស់លោកមន្ត្រីធំតូច នឹងព្រះភិក្ខុសង្ឃរាជាគណៈហានានុក្រម នឹងពុទ្ធសាសនិកជនទាំងឡាយក្នុងកម្ពុជរដ្ឋទាំងមូល ព្រមទាំង

ពុទ្ធសាសនិកជនក្នុងដៃនក្អូសាំងស៊ីនធីង បានបរិច្ចាគទ្រព្យ ប្លុលជួយតាមកំទ្រាំងសទ្ធាក៏មាន បានបរិច្ចាគទ្រព្យទទួលយក ដល់ពេញមួយបប់ ឬប្រើនបប់ក៏មាន ។

៣ ដោយប្រាក់ចំណូលផ្សេង ក្រៅអំពីប្រាក់ដែលបាន ប្តែងខាងលើនោះក៏មាន ។ ក្នុងឱកាសនេះលោកប៉ូលវ៉ាយណ្ហូទ សេនាបតី ក្រសួងត្រួតត្រាប្រទេសរាជ្យជាស្រុកចំណុះ ដែលលោកមានដំណើរអញ្ជើញពីមហានគរបារាំងសែស មកឯប្រទេសឥណ្ឌូចិន បានជ្រាបអំពីការបោះពុម្ពព្រះត្រៃបិដកនេះ លោកក៏មានអធ្យាស្រ័យត្រេកអរជាមួយផង ហើយបានបរិច្ចាគទ្រព្យរបស់លោកប្លុលជួយឧបត្ថម្ភការបោះពុម្ពនេះ ដើម្បីសំដែងឲ្យឃើញជាភ័ស្តុតាងថា លោកមានអំណរជាទីបំផុត ក្នុងការបោះពុម្ពព្រះត្រៃបិដកនេះ ។

អំពីសេចក្តីយល់ឃើញ

ដ៏ឥតសេចក្តីពេញចិត្តរបស់ក្រុមជំនុំ

យើងជាក្រុមជំនុំយល់ឃើញថា ដែលព្រះករុណាជាម្ចាស់ជីវិតជាមួយនឹងរាជការប្រតិកត្តរាត៍ បានបាត់ការបោះពុម្ពព្រះត្រៃ-

បិដកទាំងបាឡីទាំងសម្រាយភ្ជាប់ជាមួយគ្នានេះ ជាការវិសេស ប្រសើរបំផុត រាប់ជាជាកុសលដ៏ធំបណ្តាប់ អាចឲ្យឈ្មោះ ពេញទីជា បានលើកសង្គាយនា យើងកំណត់នាមការនេះថា "ទុតិយសង្គីតិ" ប្រែថា "ការលើកសង្គាយនាដ៏ប្រសើរបំផុត" ព្រោះតាំងពីសង្គាយនាជាន់ណាៗមក ក៏មិនឮមានសេចក្តីដំណាលថា ដែលបានប្រែជាសម្រាយផង ដរាបដល់ចប់ព្រះត្រៃបិដក ដូចសង្គាយនាក្នុងជាន់នេះទេ។ ដោយហេតុនេះយើងមានអំណរនឹងសេចក្តីពេញបិត្តដ៏ក្រៃលែង ដោយមានសង្ឃឹមជាប្រាកដ ដូចសេចក្តីដែលយើងថ្លែង ដោយសង្ខេបតទៅនេះ:

១ អ្នកកាន់ព្រះពុទ្ធសាសនាក្នុងកម្ពុជរដ្ឋទាំងមូល នឹងមានសេចក្តីប្រតិបត្តិត្រូវផ្សំគ្នា ព្រោះមានព្រះត្រៃបិដកនេះជាគ្រូប្រាប់ខុសត្រូវ ជាគោលចារឹកសម្រាប់អាងត្រូវគ្នាតែបែបមួយ ហើយនឹងបានកំចាត់បង់នូវរស៊ាមានប្រកាន់ខុសថាជាត្រូវនោះចេញ។

២ ព្រះត្រៃបិដកនេះទុកជាប្រទីបភ្លឺលាន់ប៉ឺភ្លឺអស់មហាដំន ឲ្យឃើញសេចក្តីខុសត្រូវជាក់មិនភាន់ប្រឡំ នាំឲ្យកើត

មានប្រាជ្ញាស្មារតីល្អ បេះរៀនខ្មាសរង្កៀស រអាស្អប់ខ្ពើមអំពើអាក្រក់ ឲ្យខ្ជិឃ្មាតសង្វាតខំប្រឹងប្រព្រឹត្តសុបរិតសួតត្រង់ ដៃល ជាពូជបង្កើតសេចក្តីសុខឲ្យមានបរិបូណ៌ទ្បើង ។ កាលបើអស់ បណ្តាជន មានសេចក្តីអៀនខ្មាស ជ្រែញចិត្តនឹងអំពើអាក្រក់ ហើយ ព្រះគគ៌ក៏នឹងប្តេជ្ញារុងរឿង មានកេរ្តិ៍ឈ្មោះក្រអូបសាយ ទៅក្នុងលោកទាំងមូល ពីព្រោះធម៌សុបរិត មានក្លិនក្រអូបជា បំផុត ជាងក្លិននៃគ្រឿងក្រអូបទាំងអស់ ។

អំពីរបៀបការរបស់ក្រុមដំណុំ

របៀបមុខការគ្រប់យ៉ាង ដៃលបានរៀបចំព្រះត្រៃបិដកនេះ យើងជាក្រុមដំណុំ បានធ្វើដោយកំទ្បាំងព្យាយាមជ៌ាំមួន ព្រម ទាំងបានពិនិត្យពិច័យ ដោយល្អិតល្អ ដូចមានសេចក្តីរាយ ដំណើរការតទៅនេះ:

១ បណ្តាព្រះត្រៃបិដក គឺព្រះវិន័យ ព្រះសូត្រ ព្រះ អភិធម្ម យើងបានចាប់រៀបចំព្រះវិន័យបិដកមុន រួចហើយ

ទើបរៀបចំព្រះសុត្តន្តបិដក ធំឯគ្រឹះវិនយបិដកតទៅ ធ្វើ
តាមរបៀបហ្នឹងហៅ គឺតាមលំដាប់គម្ពីរខ្មែរក្រោយ ។

២ យើងបានយកព្រះត្រៃបិដក អក្សរខ្មែរគម្ពីរស្លឹករឹតមក
ធ្វើជាប្បាប់ដើម បម្លងស្រង់បាឡីជាក់ក្រដាស ហើយបានយក
ព្រះត្រៃបិដកគ្រប់យ៉ាង ដែលមាននៅក្នុងព្រះរាជបណ្ណាល័យ
កម្ពុជា មកធ្វើជាប្បាប់ផ្ទៀងធៀបគ្នា ។ បើផ្ទៀងធៀបគ្នា
ទៅហើយឃើញមានបាឡីត្រង់ណាដែលធ្វើងគ្នាខ្លះ យើងបាន
ស្រង់បាឡីនោះយោងលេខមកជាក់ត្រង់កន្លែងនយលក្ខណៈ
“កំណត់ហេតុពន្យល់” ខាងក្រោមអានតំនួសខណ្ឌរាំងដោយ
ទ្បែកឯលេខដែលយោងមកនោះខាងលើធំងខាងក្រោមត្រូវគ្នា ។
គម្ពីរព្រះត្រៃបិដកប្រទេសឱរូប យើងកំណត់នាមដោយបាឡីបា
ឱរោបិយបោត្ថក ប្រើអក្សរជាអាទិសង្កេតន័យតែ១តួបា ឱ. ។
គម្ពីរភូមាបា មរម្មបោត្ថក ប្រើអាទិសង្កេតន័យបា ម. ។ គម្ពីរមន
បា រាមញ្ញបោត្ថក ប្រើអាទិសង្កេតន័យបា រ. ។ ឯព្រះត្រៃបិដក
អក្សរសៀម យើងមិនបានធ្លើយក្នុងនយលក្ខណៈទេ ព្រោះមាន

ទំនងដូចគ្នានឹងប្លាប់អក្សរខមដែរ ។ បើក្នុងប្លាប់អក្សរខមក្តី អក្សរសៀមក្តី មានបាលីធ្វើឯគ្នាខ្លះដោយអន្លើៗនោះ យើងយោងលេខធ្វើយមកក្នុងនយលក្ខណៈ ប្រាប់ដំណើរដែលធ្វើឯគ្នានោះដែរ ។

៣ លុះបានធ្វើឯបាលីដោយត្រឹមត្រូវហើយ ទើបយកបាឡីនោះមកប្រៀងសេចក្តីជាក្រោយ ។ ឯការប្រៀនោះយើងបានយកគម្ពីរអដ្ឋកថា ដីកា យោជនា មកមើលជាជំរាបដើម្បីឲ្យឃើញសេចក្តីដាក់ប្រាកដ ប៉ុន្តែមិនបានប្រែអធិប្បាយតាមន័យក្នុងអដ្ឋកថា ដីកា នោះទេ យើងប្រែតាមលំអានបាឡីព្រះត្រៃបិដកៈ "តូជើប" នោះប៉ុណ្ណោះ គឺបាបាឡីនោះមានសេចក្តីប៉ុន្មាន យើងប្រែឲ្យគត់តែត្រឹមប៉ុណ្ណោះឯង តែបើសត្វប្រយោគណា ដែលមានសេចក្តីបង្កៀតពិបាកយល់ នោះយើងបន្ថែមពាក្យ ឬសេចក្តីខ្លះ តាមន័យក្នុងអដ្ឋកថា ដីកា ដាក់ក្នុងវង់ក្រចកៈ ( ) នេះ សំគាល់ឲ្យដឹងថា ពាក្យឬសេចក្តីនោះបញ្ចូលចៃមមកៈទេ ។

ម្យ៉ាងទៀត ប្រយោគខ្លះ មានដំណើរចាប់ពីចាកប្រៃរៀងសេចក្តីសម្រួលមកជាសម្រាយនោះពេក បើលុះតែបញ្ចូលពាក្យបែមមកខ្លះ ទើបមិនងាស់សេចក្តី កាលបើដូច្នេះ យើងបញ្ចូលពាក្យបែមមកខ្លះដាក់ក្នុងវង់ក្រចក ( ) នេះ ដែរដូចជាពាក្យថា (នេះ)(នោះ)ជាដើម ដើម្បីឲ្យស្រួលតាមលំនាំសេចក្តីភាសាខ្មែរ ។

៤ ពាក្យឬប្រយោគណា ដែលមានសេចក្តីជ្រៅកំបាំងពេក បើមិនទាញយកមកអធិប្បាយឲ្យល់ផងទេ មុខជាគឹងអាចបញ្ចូលចិត្តសេចក្តីមិនបាន នោះយើងបានស្រង់យកសេចក្តីអធិប្បាយពីក្នុងអដ្ឋកថា ឬដីកា យោងលេខមកដាក់ត្រង់នយ-លក្ខណៈខាងក្រោម ដើម្បីឲ្យងាយយល់សេចក្តីជាភ័ក្រាកដឡើងបាន ។

៥ លុះប្រែរួចបម្លងសម្រេចស្រេចហើយ យើងបានប្រជុំគ្នាធ្វើងផ្ទាត់យល់ព្រមថាត្រឹមត្រូវហើយ ក៏ជូនសេចក្តីបម្លងបាន្តឹតឹងសម្រាយនោះ ប្តូលទៅអស់លោកកុងស៊ីយ៉ែសេនាបតីតាម

ក្រសួង គ្រាតែបានអនុញ្ញាតអំពីលោកឡឺរេស៊ីដង់ត៍ស៊ុប៉ែរីយើរ
ឆ័ងអស់លោកកុងស៊ីយ៍សេនាបតី ព្រមទាំងសម្តេច ព្រះសង្ឃ-
នាយកទាំងពីរគណៈស្រេចហើយ ទើបរាជការចាត់ចែងឲ្យ
បោះពុម្ពគ្នៅ ។

៦ ក្នុងកាលដែលបោះពុម្ពព្រះត្រៃបិដកនេះ រាល់សៀវ-
ភៅទាំងអស់ យើងបានធ្វើឯកិច្ចសាពុម្ព ដោយប្រុងប្រយ័ត្ន
ពិនិត្យពិចារណាមាំមួនណាស់ តែជាធម្មតាការបោះពុម្ពប្រើនដង
ម្ល៉ះ បើទុកជាពិនិត្យពិចារណាយ៉ាងណា ក៏គង់តែនៅមានភ្លាត់
ខ្វុសខ្វះបន្តិចបន្តួចមិនលែង ។

បឋមោ ភាគោ

ឆមោ តណ្ហុ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេរញ្ជកណ្ឌំ

[១] តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ
វិហរតិ នឡេរុបុចិមន្ទមូលេ មហតា ភិក្ខុសង្ឃេន សទ្ធឹ
បញ្ចមត្តេហិ ភិក្ខុសតេហិ ។ អស្សោសិ ខោ វេរញ្ជោ
ព្រាហ្មណោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ
សក្យកុលា បព្ពជិតោ វេរញ្ជាយំ វិហរតិ នឡេរុបុចិ-
មន្ទមូលេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ
ភិក្ខុសតេហិ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ
កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ
ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ

ភាគទី ១

សូមធម៌ស្តារប្ញើបបង្គំ បំពោះព្រះដ៏មានព្រះភាគជាអរហន្ត សម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

វេរញ្ជកណ្ឌ

[១] សម័យនោះ ព្រះសម្មុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នាឡុយក្ស ជិតស្រុកវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍(១) បានឮច្បាស់ (នូវដំណឹងនោះហើយ ទើបប្រកាសសេចក្តីថា) ម្នាលគ្នាយើង បានឮថា ព្រះសមណគោតម ជាសក្យបុត្រចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវមកគង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នាឡុយក្ស ជិតស្រុកវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ កិត្តិសព្ទដ៏ពីពេរបស់ព្រះគោតមដ៏ចំរើននោះ ពួកខ្ញុំព្រះអង្គាយ សុះសាយ យ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គផ្ទាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ថា វិជ្ជាចរណសម្បន្នោ

, ១ ក្នុងអដ្ឋកថា ថា ព្រាហ្មណ៍នេះឈ្មោះ ឧទយៈ ដែលហៅថា វេរញ្ជៈ គឺហៅតាមឋានស្រុកវេរញ្ជាជាស្រុករបស់គាត់នៅ ។

ថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០៦

สุภเถเร โลกวิทู ภควนฺตเก ปุริสทมฺมสารถิ สตฺถา
เทวมนุสฺสานํ พุทฺโธ ภควาติ เสา ๙ทิ โลกาทิ
สเทวกา สมารกา สพฺรหฺมกา สสฺสมณพฺราหฺมณิ
ปชา สเทวมนุสฺสา สยเมว อภิญฺญา สจฺฉิกตฺวา ปเวเทติ
เสา ธมฺมิ เทเสติ อาทิกลฺยาณิ มชฺฌกลฺยาณิ
ปริโยสานกลฺยาณิ สาตฺถิ สพฺยญฺชนิ เกวล-
ปริปุณฺณิ ปริสุทฺธิ พฺรหฺมจริยิ ปกาเสติ สาธุ
โข ปน ตถารูปานิ อรหตา ทสฺสนิ โหตีติ ฯ

(๒) อถโข เวเทหา พฺราหฺมณา เยน
ภควา เตนุปสงฺกมิ อุปสงฺกมิตฺวา ภควตา
สทฺธิ สมฺโมทิ สมฺโมทนียิ กถิ

ព្រោះព្រះអង្គបរិបូណ៌ ដោយវិជ្ជានិងចរណៈគឺសេចក្តីចេះដឹងនិងកិរិយាដែលបុគ្គលគប្បីប្រព្រឹត្ត ថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ ទៅកាន់ព្រះនិព្វាន ថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ថា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ថា ភគវា ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់កំណើតថ្មីទៀត ព្រះអង្គបានត្រាស់ដឹង ហើយទ្រង់ប្រកាសបំភ្លឺបំពោះព្រះអង្គនូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក បំពោះពួកសត្វ ទ្រង់ញុំាងនូវពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយទ្រង់ប្រកាស ទ្រង់សំដែងធម៌ ពីពេះបទដើម បទកណ្តាលនិងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញ បានដួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងហ្នឹង ជាការប្រពៃពេក ។

(๒) គ្រានោះ វេរញ្ជព្រាហ្មណ៍ក៏ចូលសំដៅទៅត្រង់ទីដែលព្រះដ៏មានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះ

สมาสนิยเมน วิคฺคหวากฺยานิ ปกฺขิปิตฺวา ปกฺขิปิตฺวา ฉินฺทิตพฺพานิ ฉินฺทิตฺวา ฉินฺทิตฺวา ปทมาลา สมฺปาทิตพฺพา สุตฺตปฺปเทสุ ปเน เอตฺตกมฺปิ อวตฺวา เอตฺตโก ปเนตฺถ วินิจฺฉโย เอตฺตโก สมาสวิคฺคโห เอตฺตกา ปทมาลา ปทตฺถา[1] ปกาสิตา อนฺตเร ปเนตฺถ อนุปฺปตฺเต อกิจฺจเกติ จ ปตฺวาเทติ จ อาสเนน จ ฉินฺนตนฺตีติ จ ตยิทนฺ เอตฺตก เอตฺถ จ ยาว จ ตาว อนุปฺปตฺเต อกิจฺจเกติ จ ปตฺวาเทติ จ อาสเนน จ ฉินฺนตนฺตีติ จ ตยิทนฺ เอตฺตก จ สมฺปฺปเตติ จ นามนฺติ เอตฺถ ปกาสิตา สเนวาเถร เอวาเถร สมาวาเถร ลเฆฺวเถร สสฺสมฆา-

---

๑ ม. ปทตฺถ ๑

សំណាលនៅកន្លែងដ៏មានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួរនឹងពាក្យដែលគួរលឹកឡើងឲ្យកើតសេចក្តីសិនិទ្ធស្មោលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ កាលដែលវេរញ្ជព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ក៏ផ្តើមពាក្យនេះក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំបានឮពាក្យថា ព្រះសមណគោតម មិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ចាស់ឆ្កួយដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកកន្លងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅវេរញ្ជព្រាហ្មណ៍ទំនងនោះឲ្យអង្គុយលើអាសនៈ (ព្រះអង្គក៏មិនធ្លាប់) បពិត្រព្រះគោតមដ៏ចំរើន ពាក្យដែលខ្ញុំបានឮមកនោះ ជាប្រាកដថា ព្រះគោតមដ៏ចំរើន មិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ចាស់ឆ្កួយដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកកន្លងបច្ឆិមវ័យហើយ ថា សូម្បីត្រឹមតែអញ្ជើញហៅវេរញ្ជព្រាហ្មណ៍ចាស់នោះឲ្យអង្គុយលើអាសនៈ (ព្រះអង្គក៏មិនធ្លាប់) បពិត្រព្រះគោតមដ៏ចំរើន កិច្ចមានមិនសំពះជាដើមនោះ ជាទំនងពុំសមគួរឡើយ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណៈ

ព្រាហ្មណាយ បជាយ សនេវមនុស្សាយ យមហំ
អភិវាទេយ្យំ វា បច្ចុដ្ឋេយ្យំ វា អាសនេន វា និមន្តេយ្យំ
យំ បាំ ព្រាហ្មណា តថាគតោ អភិវាទេយ្យ វា
បច្ចុដ្ឋេយ្យ វា អាសនេន វា និមន្តេយ្យ ឥទ្ធាបិ តស្ស
វិបាកេយ្យាតំ ។ អារសុរចោ ភវំ គោតមោតំ ។ អត្ថំ ខ្វេស
ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទ-
មានោ វទេយ្យ អារសុរចោ សមណោ គោតមោតំ យេ
តេ ព្រាហ្មណ រូបរសា សទ្ទរសា គន្ធរសា រសរសា
ផោដ្ឋព្វរសា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលា-
វត្ថុកតា អនភាវំ កតា[1] អាយតឹ អនុប្បាទធម្មា អយំ
ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា
វទមានោ វទេយ្យ អារសុរចោ សមណោ គោតមោតំ

---

๑ ឥតាតំបិ ជាឡេ ។

ទីឆ៌ព្រាហ្មណ៍ ពាក្យដ៏មានមនុស្សជាសម្មតិទេព ទីឆ៌មនុស្សជ័រសេស តថាគត
មិនឃើញអ្នកណាមួយ ល្មមឲ្យតថាគតសំពះ ឬក្រោកទទួល ឬអញ្ជើញ
ហៅរកឲ្យអង្គុយលើអាសនៈនោះឡើយ ម្នាលព្រាហ្មណ៍ ព្រោះថា
បើតថាគតសំពះអ្នកណា ឬក្រោកទទួលអ្នកណា ឬអញ្ជើញហៅរក
អ្នកណាឲ្យអង្គុយលើអាសនៈ ក្បាលរបស់អ្នកនោះ ទីឆ៌ជាច់ធ្លាក់ចេញ
ចាកក ។ រៀរញ្ជព្រាហ្មណ៍ ក៏ពោលពាក្យច្រែងច្រោះ ទៅរកព្រះ
សាស្តាថា ព្រះគោតមដ៏ចំរើន ជាមនុស្សសោះកក្រោះ ឥតរសជាតិ
ទេតើ ។ ព្រះដ៏មានព្រះភាគច្រឹត្រាស់តបថា ម្នាលព្រាហ្មណ៍
ពិតមែន មានហេតុជាច្រើនឯ តួរឲ្យអ្នកផងគេថា ព្រះសមណគោតមជា
មនុស្សសោះកក្រោះ ឥតរសជាតិ ដែលគេថានោះត្រូវហើយ ម្នាល
ព្រាហ្មណ៍ ពីព្រោះរសជាតិ គឺ រូប សំឡេង ក្លិន ឧជារស សម្ផស្ស
ទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់
អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីងដូចជាដើមត្នោត
ដែលគេកែបែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ ជាធម្មតាលែង
មានបែបភាពតទៅទៀតហើយ ជាធម្មតាលែងមានកំណើតតទៅខាងមុខ
ទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម
ជាមនុស្សសោះកក្រោះ ឥតរសជាតិនោះ គឺត្រូវត្រឹមហេតុនេះឯង

เตา ๒ เตา ยำ ตุมฺเห สทฺทหถ ปเตฺตยถ ๆ อิเมหิ
ภวำ โคตมเมว ๆ อตฺถิ โขฺว ปน พฺราหฺมณา ปร-
ยาเยา เยน มำ ปริยาเยน สมฺมา วทมาโน
วเทยฺย อิเมหิ สมณา โคตมเมว เย เต
พฺราหฺมณา รูปโคตา สทฺทโคตา ตนฺตโคตา ราส-
โคตา ชาติปถโคตา เต ตถาคตสฺส ปหีนา อุจฺฉิน-
มูลา ตาลาวตฺถุกตา อนภาวำ กตา อายตึ
อนุปฺปาทธมฺมา อยำ เตา พฺราหฺมณา ปริยาเยา เยน
มำ ปริยาเยน สมฺมา วทมาโน วเทยฺย อิเมหิ
สมณา โคตมเมว เตา ๒ เตา ยำ ตุมฺเห สทฺทหถ
ปเตฺตยถ ๆ ยถาปริยาปนฺเน ภวำ โคตมเมว ๆ

ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន គ្មានគ្រឿងបរិភោគទេតើ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាច្រើន គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សគ្មានគ្រឿងបរិភោគ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះគ្រឿងបរិភោគ គឺរូប សំឡេង ក្លិន រស សម្ផស្សទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើតុសម្រាប់កើតទៀតឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេកែបែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ ជាធម្មតាលែងមានបែបភាពតទៅទៀតហើយ ជាធម្មមិនមានកំណើតតទៅខាងមុខទៀតទេ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សគ្មានគ្រឿងបរិភោគនោះ គឺជាសំដីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន ជាអ្នកពោលពាក្យឃាត់កិច្ចការ ថាមិនត្រូវធ្វើទេតើ ។

អត្ថំ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកតិរិយាវាទោ សមណោ គោតមោតំ អហញ្ចិ ព្រាហ្មណ អកតិរិយំ វទាមិ កាយទុច្ចរិតស្ស វចីទុច្ចរិតស្ស មនោទុច្ចរិតស្ស អនេ-កវិហិតានំ ចាបកានំ អកុសលានំ ធម្មានំ អកតិរិយំ វទាមិ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយា-យេន សម្មា វទមានោ វទេយ្យ អកតិរិយាវាទោ សមណោ គោតមោតំ នោ ច ខោ យំ ត្វំ សញ្ញាយ វទេសិតំ ។ ទុច្ចេនវាទោ អវំ គោតមោតំ ។ អត្ថំ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ទុច្ចេនវាទោ សមណោ គោតមោតំ អហញ្ចិ ព្រាហ្មណ ទុច្ចេនំ វទាមិ រាគស្ស ទោសស្ស មោហស្ស អនេកវិហិតានំ ចាបកានំ អកុសលានំ ធម្មានំ

ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាច្រើន តួវឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ តថាគតប្រកាន់និយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយ ធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតឡើយ តថាគតតែងនិយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយ ធ្វើនូវធម៌ជាំងឡាយជាអកុសលដ៏ក្រៃលែនប្រការនោះឡើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើនោះ គឺជាសំដីត្រូវតែងហេតុនេះឯង ប៉ុន្តែមិនមែនត្រូវតែងហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិលទេតើ ។ ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាច្រើន តួវឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិល ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ តថាគតប្រកាន់និយាយថា ឲ្យសត្វកាត់ផ្តាច់ផ្តិលនូវរាគៈ ទោសៈ មោហៈ តថាគតតែងនិយាយថា ឲ្យសត្វកាត់ផ្តាច់នូវធម៌ជាំងឡាយ ជាអកុសលដ៏អាក្រក់ ច្រើនយ៉ាងនោះចេញ

ឧបេច្ច វន្ទាមិ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧបេច្ច ឯនោ សមណោ គោតមោតិ នោ ច ខោ យំ តុំ សង្ឃាយ វទេសីតិ ។ ដេកុច្ច ភវំ គោតមោតិ ។ អត្ថំ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ដេកុច្ច សមណោ គោតមោ-តិ អហញ្ចិ ព្រាហ្មណ ដិកុច្ចាមិ[1] តាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន អនេកវិហិតានំ ទាបតានំ អកុសលានំ ឯម្ហានំ សមាបត្តិយា ដិកុច្ចាមិ[1] អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ដេកុច្ច សមណោ គោតមោតិ នោ ច ខោ យំ តុំ សង្ឃាយ វទេសីតិ ។ វេនយិកោ ភវំ គោតមោតិ ។ អត្ថំ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិ-កោ សមណោ គោតមោតិ ។ អហញ្ចិ ព្រាហ្មណ វិនយាយ ឯម្ហំ ទេសេមិ ភគស្ស នោ សស្ស មោ មាស្ស

---

១ ឥមេសុ ទ្វីសុ ឋានេសុ ដេគុច្ឆំ វិកាមីតិបិ ពាហៅ ទិស្សតិ ។

ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យផ្តាច់ផ្តិលនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន ជាអ្នកខ្ចីមរអើមណាស់ ទេតើ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ចីមរអើម ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ តថាគតខ្ចីមសេចក្តីប្រព្រឹត្តិអាក្រក់ ដោយកាយ វាចា ចិត្ត តថាគតខ្ចីមសេចក្តីប្រកបចិត្តផ្តេកផ្តិតទៅរកអកុសលធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការ (នោះណាស់) ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ចីមរអើមនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន ជាអ្នកបំផ្លាញទេតើ ។ ព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកបំផ្លាញ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ តថាគតសំដែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែលបំផ្លាញបង់នូវរាគៈ ទោសៈ មោហៈ

อเนกวิเธ นานปฺปการเก อกุสลานํ ธมฺมานํ
วินยาย ธมฺมํ เทเสติ อยํ เขา พฺราหฺมณ ปริยา-
เยา เยน มํ ปริยาเยน สมฺมา วเทมาโน วเทยฺย
วเทยฺโย กา สมโณ โคตมโต นาม ธ เขา ยํ ตุ
สทฺธาย วเทสีติ ฯ ตปสฺสี กาโร โคตมโต ฯ
อตฺถ เขฺว พฺราหฺมณ ปริยาเยา เยน มํ ปริยา-
เยน สมฺมา วเทมาโน วเทยฺย ตปสฺสี สมโณ
โคตมโต ตปนียาหิ พฺราหฺมณ ธาปเก อกุ-
สเล ธมฺเม วทามิ กายทุจฺจริตํ วจีทุจฺจริตํ มโนทุจฺจริตํ
ยสฺส เขา พฺราหฺมณ ตปนียา ธาปกา อกุสลา
ธมฺมา ปหีนา อุจฺฉินฺนมูลา ตาลาวตฺถุกตา อนภาวं
กตา อายตึ อนุปฺปาทธมฺมา ตมหา ตปสฺสีติ
วเทมิ ตถาคตสฺส เขา พฺราหฺมณ ตปนียา
ธาปกา อกุสลา ธมฺมา ปหีนา อุจฺฉินฺนมูลา

ពាក្យគេតសំដែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែលរំលងបង់នូវអកុសលធម៌ទាំង
ឡាយដ៏អាក្រក់ច្រើនប្រការ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះ
សមណគោតម ជាអ្នកបំផ្លាញនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែន
ត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ក្រោល
ថា ព្រះគោតមដ៏ចំរើន ជាអ្នកជុតកំដៅទេតើ ។ ព្រះសព្វញ្ញូជាម្ចាស់
ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាខ្នងឯង គួរឲ្យអ្នក
ផងគេថា ព្រះសមណគោតមជាអ្នកជុតកំដៅ ដែលគេថានោះត្រូវហើយ
ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រកាន់និយាយថា ការប្រព្រឹត្តិអាក្រក់
ដោយកាយ វាចា ចិត្ត ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ជាអកុសលធម៌ដ៏
អាក្រក់ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលជាទីតាំងនៃសេចក្តីក្តៅ
ក្រហាយ (នោះ) បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫស
តល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីងដូចដើមត្នោត
ដែលគេកែបែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែង
មានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខ
ទៀតហើយ តថាគតហៅអ្នកនោះថា អ្នកជុតកំដៅ ម្នាលព្រាហ្មណ៍
អកុសលធម៌ទាំងឡាយដ៏អាក្រក់ជាទីតាំងនៃសេចក្តីក្តៅក្រហាយ (នោះ)
តថាគតឯងបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសតល់អស់ហើយ

ตาลาวตฺถุกตา อนภาวํ กตา อายตึ อนุปฺปาท-
ธมฺมา อยํ เม พฺราหฺมณ ปริยาเยน เจว มํ
ปริยาเยน สมฺมา วทมาโน วเทยฺย ตปสฺสี
สมโณ โคตมโต นาม จ เม ยสฺ สทฺธาย
วเทยฺยาติ ฯ อปตฺถเก หิ โคตมโต ฯ อตฺถิ เขฺว
พฺราหฺมณ ปริยาเยน เจว มํ ปริยาเยน สมฺมา
วทมาโน วเทยฺย อปตฺถเก สมโณ โคตมโต
ยสฺส เม พฺราหฺมณ อายตึ ปฏิสนฺธิยา
ปุนพฺภวาภินิพฺพตฺติ ปหีนา อุจฺฉินฺนมูลา ตาลาวตฺถุกตา
อนภาวํ กตา อายตึ อนุปฺปาทธมฺมา ตมหํ
อปตฺถิกตฺวา วทามิ ตถาคตสฺส เม พฺราหฺมณ อายตึ
ปฏิสนฺธิยา ปุนพฺภวาภินิพฺพตฺติ ปหีนา อุจฺฉินฺนมูลา

ជាន់ខ្ពស់ក្នុងសម្រាប់កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេកាត់ចៃលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ ជាន់ធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម្មលែងមានកំណើតតទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកដុតកំដៅនោះគឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯង្គនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចំរើន ជាមនុស្សត្រឹតកំណើតទេតើ។ ព្រះដ៏មានជាគ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែនហើយ មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សត្រឹតកំណើត ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះកិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងគភ៌តទៅមុខទៀត បើអ្នកណាបានលះបង់ស្រឡះហើយ ជាន់ផ្តាច់ផ្តិលឫសគល់អស់ហើយ ជាន់ធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេកាត់ចៃលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ ជាន់ធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម្មលែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា អ្នកឥតកំណើត ម្នាលព្រាហ្មណ៍ កិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងគភ៌តទៅមុខទៀត (នោះ) តថាគតឯង៎ជាន់លះបង់ស្រឡះហើយ ជាន់ផ្តាច់ផ្តិលឫសគល់អស់ហើយ

ตาณาวตฺตกรา อนตาโร กตา อายสฺมา อนุรุทฺธนฺติ
อยญฺเจ พฺราหฺมณา ปริยาเยน ยเทว มยา ปริยา-
เยน สทฺธา วิหิตาเยว ภิยฺยา อปตฺติกา สรณาย
เจตาปิตา จ เจ ยญฺจ สทฺธาย วิเนยฺยาติ ฯ

(๓) เสยฺยถาปิ พฺราหฺมณา กุกฺกุฏิยา อณฺฑานิ
อฏฺฐ วา ทส วา ทฺวาทส วา ตานสฺสุ กุกฺกุฏิยา
สทฺธา อธิสยิตานิ สทฺธา ปริเสทิตานิ สทฺธา
ปริภาวิตานิ เยหิ นุ โข เตสํ กุกฺกุฏจฺฉาปกานิ
ปฐมตรํ ปาทนขสิขาย วา มุขตุณฺฑเกน วา
อณฺฑกোสํ ปทาเลตฺวา สোตฺถินา อภินิพฺภิชฺเชยฺยุ
กินฺติ สฺวาสฺสุ วจนียา เอเตฺถว วา กรินฺเถว วนฺติ ฯ
เอเตฺถตสฺส ภควา เจตสา เจตปริยายมาชานาติ เอส
เหตฺถ เจตสา เจตปริยายมาชานาติ ยาว อรหตฺตมฺปิ ฯ
เอวเมว โข อหญฺจ พฺราหฺมณา อิมาสญฺจ
อาปตฺติกฺขนฺธานญฺจ วุฏฺฐานาย ปฏิญฺญาย

បានធ្វើវត្តសម្រាប់កើតទៀត ឲ្យអស់លើង ដូចជាដើមត្នោត ដែលគេ
កែ្រលែគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមាន
បែបភាពតទៅទៀតហើយ ឲ្យដាច់បែលែងមានកំណើតតទៅខាងមុខទៀត
ហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកដឹងគេថា ព្រះសមណៈគោតម ជា
មនុស្សត្រឹតកំណើតនោះ ពិត្រូវត្រែង់ហេតុនេះឯង ប៉ុន្តែបុគ្គលមែនត្រូវត្រែង់
ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។

(៣) ម្នាលព្រាហ្មណ៍ ប្រៀបដូចជាពងមាន់ទាំង ៣ ក្តី ១០ ក្តី
១៦ ក្តី ពងមាន់ទាំងនោះ ពីមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់
ក្តៅដោយប្រពៃហើយ ឲ្យចាប់ភ្ញុំពងជាមេដោយប្រពៃហើយ (លុះដល់
វេលាញាស់) កំបណ្តាកូនមាន់ទាំងនោះ កូនមាន់ណា មុំឈាយសម្បក
ពង ដោយចុងក្រចកដើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយ
ស្រួលមុនគេបំផុត បើដូច្នេះតើ អ្នកផងគួរហៅកូនមាន់នោះថា កូនច្បង
ឬកូនពៅហ៎ំ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចំរើន
(កូនមាន់នោះ) គេគួរហៅថា កូនច្បង ព្រោះវាជាបងគេបំផុត ។ ព្រះ
សាស្តាទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ កាលបើពួកសត្វ ដូចជាពង
ហាន់ កើតហើយ មានវិជ្ជាគឺសេចក្តីស្ងប់ ដូចជាសម្បកពងកំពុងរួបរឹត

อาวุโสคาโคสมา ปธานวิรหิตา ฯเปฯ อนุตฺตรา สมฺมาสมฺโพธิ อหเมสมฺหิ สมฺมาสมฺโพธิ เสยฺยถาปิ พฺราหฺมณา เอวเมว พฺราหฺมณา ปาจีนโต อาคจฺฉนฺติ ปจฺจุคฺคมนาย อหเมวมสฺมิ ปจฺจุคฺคโต นาหเมตฺถ พฺราหฺมณา อาคจฺฉามิ นิสีทนฺติ พฺราหฺมณา อาสนานิ ปญฺญาเปนฺติ ปาทา ธุวนฺติ ปาทา มกฺขนฺติ ปาทา ปาทปีฐานิ ปาทกถลิกา อุปนิกฺขิปนฺติ อหเมตฺถ พฺราหฺมณา นิสีทามิ ยถา ตถา ตตฺถ ยาทิสา ตาทิสา ปุพฺเพ ตาทิสา ปจฺฉา ยาทิสา ปจฺฉา ตาทิสา อิทานิ ยาทิสา อิทานิ ตาทิสา อนาคเตปิ ยาทิสา อนาคเต ตาทิสา ตสฺมาติห พฺราหฺมณา เอวญฺจ เอวญฺจ สิกฺขิตพฺพนฺติ ฯ

ตตฺถ ปธานวิรหิตาติ ปธานวิรหิตา ปธานวิรหิตา ปธานวิรหิตา

ក្នុងលោក មានតែតថាគតម្នាក់ឯង ដែលទំលាយសម្បកពង គឺសេចក្តីល្ងង់ ហើយត្រាស់ដឹងខ្លួនឯង ដោយប្រពៃ នូវសម្មាសម្ពោធិញ្ញាណ ដែលមិនមានគុណជាតឯទៀត ប្រសើរជាងឡើយ ម្នាលព្រាហ្មណ៍ តថាគតឯងជាចម្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក ម្នាលព្រាហ្មណ៍ ព្យាយាមតថាគតបានតាំងផ្តើមហើយ មិនបន្ធូរបន្ធយទេ តាំងស្មារតី តថាគតក៏ប្រឹងមិនឲ្យមានក្ងាត់ កាយសោតក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏ឋិតល្អជាចិត្តមានអារម្មណ៍តែមួយ ម្នាលព្រាហ្មណ៍ តថាគតឯង លុះដល់ច្រកដ ជាស្ងាត់ចាកកាមទាំងឡាយ ច្រកដជាស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលហើយ ក៏ចូលដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈវិចារៈ មានបីតិនឹងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍នៅហើយ ។ លុះតថាគតចូលទៅជិតរម្ងាប់វិតក្កៈ វិចារៈ រួចហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាទីផូរផង់ប្រព្រឹត្តទៅខាងក្នុង មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈវិចារៈ មានតែបីតិនឹងសុខ កើតពីសមាធិនៅហើយ ។ លុះលះបង់បីតិចេញហើយ តថាគតជាបុគ្គលព្រងើយ ចាន់សតិមានសេចក្តីដឹងច្បាស់នៅហើយ តថាគតរសោយសុខដោយកាយផង អរិយបុគ្គលតាំងឡាយ តែងសំដែងនូវបុគ្គល ដែលបានតតិយជ្ឈានណាថា ជាបុគ្គលមានចិត្តព្រងើយ

สตินฺทฺริยพลโพชฺฌงฺคมคฺคงฺคานิ ฉ ผสฺสาทโย ปญฺจ ขนฺธา ทฺวาทสายตนานิ อฏฺฐารส ธาตุโย ทุกฺขสจฺจนฺติ ปชานาติ ฯ ตณฺหา ปุนพฺภวิกา นนฺทีราคสหคตา ตตฺรตตฺราภินนฺทินี เสยฺยถีทํ ฯ กามตณฺหา ภวตณฺหา วิภวตณฺหา รูปตณฺหา อรูปตณฺหา นิโรธตณฺหา ทิฏฺฐิคตานิ ฉ ผสฺสาทโย ปญฺจ ขนฺธา ทฺวาทสายตนานิ อฏฺฐารส ธาตุโย สมุทยสจฺจนฺติ ปชานาติ ฯ ตสฺเสว ตณฺหาสงฺขาตสฺส สมุทยสฺส อปฺปวตฺติ นิโรธสจฺจนฺติ ปชานาติ ฯ ตณฺหานิโรธาย ปฏิปทา อริยมคฺโค เสยฺยถีทํ ฯ สมฺมาทิฏฺฐิ สมฺมาสงฺกปฺโป สมฺมาวาจา สมฺมากมฺมนฺโต สมฺมาอาชีโว สมฺมาวายาโม สมฺมาสติ สมฺมาสมาธิ ฉ ผสฺสาทโย ปญฺจ ขนฺธา ทฺวาทสายตนานิ อฏฺฐารส ธาตุโย ทุกฺขนิโรธคามินิปฏิปทาสจฺจนฺติ ปชานาติ ฯ ตสฺเสว ตณฺหาสงฺขาตสฺส สมุทยสฺส อปฺปวตฺติ นิโรธสจฺจนฺติ ปชานาติ ฯ ตณฺหานิโรธาย ปฏิปทา อริยมคฺโค เสยฺยถีทํ ฯ สมฺมาทิฏฺฐิ สมฺมาสงฺกปฺโป สมฺมาวาจา สมฺมากมฺมนฺโต สมฺมาอาชีโว สมฺมาวายาโม สมฺมาสติ สมฺมาสมาธิ ฉ ผสฺสาทโย ปญฺจ ขนฺธา ทฺวาทสายตนานิ อฏฺฐารส ธาตุโย ทุกฺขนิโรธคามินิปฏิปทาสจฺจนฺติ ปชานาติ ฯ อิติ อชฺฌตฺตา วา ธมฺมานุปสฺสี วิหรติ ฯ พหิทฺธา วา ธมฺมานุปสฺสี วิหรติ ฯ อชฺฌตฺตพหิทฺธา วา ธมฺมานุปสฺสี วิหรติ ฯ สมุทยธมฺมานุปสฺสี วา ธมฺมสฺมึ วิหรติ ฯ วยธมฺมานุปสฺสี วา ธมฺมสฺมึ วิหรติ ฯ สมุทยวยธมฺมานุปสฺสี วา ธมฺมสฺมึ วิหรติ ฯ อตฺถิ ธมฺมาติ วา ปนสฺส สติ ปจฺจุปฏฺฐิตา โหติ ยาวเทว ญาณมตฺตาย ปฏิสฺสติมตฺตาย ฯ อนิสฺสิโต จ วิหรติ น จ กิญฺจิ โลเก อุปาทิยติ ฯ เอวมฺปิ ภิกฺขุ ธมฺมานุปสฺสี วิหรติ ฯ

๑ ฉ. ม. อนญฺญาตญฺญสฺสามีติ ฯ

ជាអ្នកមានស្មារតី មានប្រក្រតីនៅជាសុខ ឥឡូវតថាគតក៏បានដល់នូវតតិ-
យជ្ឈាននោះហើយនៅ ។ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះ
បង់នូវសេចក្តីទុក្ខផង ព្រោះរំលត់នូវសោមនស្សទំនឹងទោមនស្ស អំពីមុន
ផង តថាគតបានចូលដល់ចតុត្ថជ្ឈានឥតទុក្ខ ឥតសុខ មានសតិដ៏ស្អាត
ព្រោះឧបេក្ខាហើយនៅ ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិន
មានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម
ជាចិត្តទឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ តថាគតឯង ក៏បាន
បង្អោនចិត្តបួលទៅ ក្នុងបុព្វេនិវាសានុស្សតិញ្ញាណ (ញាណជាគ្រឿង
រលឹកជាតិមុនបាន) ។ តថាគតឯង ក៏រលឹកជាតិដែលបានអាស្រ័យនៅ
មកអំពីមុន ជាអនេកជាតិ ។ រលឹកជាតិបានដូចម្តេច ។ រលឹកបាន
១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ
៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន រលឹក
បានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះ
ថា តថាគតបានកើតក៏ឯកតថាណោះ មានឈ្មោះយ៉ាងនេះ មាន
គោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួល
សុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ តថាគតច្យុតចាកអត្តភាពនោះ

อมุตฺร ขุทฺธาธิ ตตฺราหาสิ ฯ ปาณาเปา ฯ ปาตเกา ฯ ปาณ-
ฆาตา ฯ มหาเปา ฯ สุขทุกฺขปฏิสเวที ฯ มายุปาย-
ยาเปา ฯ ตโต จุโต ฯ ปทูปปชฺชิ ฯ ตตฺ สาหารา
สุขเวทิ อเนกวิเธ ปุพฺเพนิวาสา อนุสฺสรามิ ฯ
อยา เม ปฐมา พฺราหฺมณา ปฐวิยา ปฐเม ยาเม
ปฐมา วิชฺชา อวิชฺชา วิหตา วิชฺชา อุปฺปนฺนา
ตโม วิหโต อาโลโก อุปฺปนฺโน ยถา อปฺป-
มตฺตสฺส อาตาปิโน ปหิตตฺตสฺส วิหรโต ฯ อยา
เม ทุติยา พฺราหฺมณา ปฐมา อภิชาติ อโหสิ
กุกฺกุฏปฺปโตกสฺเสว อณฺฑโกสสฺมา ฯ โส ปาฏิ สมา-
ปชฺชิ ฯ ปาตเต ปาฏิสนฺธิ ปาฏิโยคาเต อนนฺตเร ปาตฺ

ហើយបានទៅកើតក្នុងកាលណោះ ដែលទៅកើតក្នុងកាលនោះ តថាគត
ក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ
មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់
អាយុប៉ុណ្ណោះ តថាគតឯងច្យុតចាកអត្តភាពនោះហើយ មកកើតក្នុង
កាលនេះ ។ តថាគតរលឹកតាមនូវជាតិ ដែលអាស្រ័យនៅពីមុន បានច្រើន
ជាតិ ព្រមទាំងអាការៈព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលព្រាហ្មណ៍
បឋមវិជ្ជានេះហើយ ដែលតថាគតបានត្រាស់ដឹង ក្នុងយាមជាដំបូងនៃរាត្រី
លុះដល់សេចក្តីលង្ងិតបាត់ទៅ សេចក្តីចេះដឹងក្រៀកដ ក៏កើតឡើង
ឯងឹតបាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលកំពុងអប្តុយប្រឹង
ស្មារតី មិនប្រហែសឆ្ងេរឆ្ងាំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្តុងឥត
មានទឹកនាដល់កាយនឹងដីរឹតឡើយ ដូចជាបណ្តិតទាំងឡាយ ដែលបាន
នូវបឋមវិជ្ជាន៎ុះដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាបឋមវិជ្ជាដែល
តថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ញាស់ចេញចាកសម្បុកពង ។
កាលដែលចិត្តខ្ចាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តី
សៅហ្មង ជាចិត្តទន់សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាង
នេះហើយ តថាគតទើបបង្អោនចិត្តចូលទៅកាន់ញាណ ដែលនាំឲ្យបាន
ត្រាស់ដឹងនូវចុតិនិងបដិសន្ធិនៃសត្វទាំងឡាយ គឺចុតូបបាតញាណ ។

សោ ធម្មេ បក្ខិត្តា វិសុទ្ធេ អតិក្កន្តមានុសកេ សត្តេ បស្សតិ ទិព្ពេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្ពណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ អយេ វត កោដ្ឋោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបន្នា អយេ វា បន កោដ្ឋោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា សុគតិំ សគ្គំ លោកំ[1] ឧបបន្នាតិ ។ ៧តិ ធម្មេន បក្ខិត្តា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ

---

1 សព្ពលោកន្តរិបិ បាឋោ ។

តថាគតពិចារណាមើលនូវសត្វតាំងខ្លាយ ដែលច្យុតទំងចាប់បដិសន្ធិនាប
ថោតនឹងទុគ្គម មានសណ្ឋានល្អនឹងអាក្រក់ ទៅកាន់សុគតិទឹងទុគ្គតិ
ដោយចក្ខុ ដូចជាទិព្វដ៏បរិសុទ្ធ កែលែងជាងចក្ខុរបស់មនុស្សសាមញ្ញ
តំយើញច្បាស់នូវសត្វតាំងខ្លាយ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎
សត្វតាំងអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត
ប្រកបដោយមនោទុច្ចរិត ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្ម ជាមិច្ឆាទិដ្ឋិ
និយាយតំះដៀលអរិយបុគ្គលតាំងខ្លាយ សត្វតាំងនោះ លុះដល់រំលាង
ខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើតឯអបាយ(១) ទុគ្គតិ(២)វិនិបាត(៣)
នរក(៤)មួយសោត អើហ្ន៎ សត្វតាំងអម្បាលនេះ ប្រកបដោយកាយ-
សុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសម្មាទិដ្ឋិ
ប្រកាន់មាំនូវកម្ម ជាសម្មាទិដ្ឋិ មិនតំះដៀលអរិយបុគ្គលតាំងខ្លាយ សត្វ
តាំងអម្បាលនោះ លុះដល់រំលាងខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើត
ក្នុងលោកគឺសុគតិ(៥)ទឹងស្ថានសួគ៌(៦) ។ តថាគតពិចារណាមើលនូវ
សត្វតាំងខ្លាយ ដែលច្យុតទំងចាប់បដិសន្ធិ នាបថោកនឹងទុគ្គម

---

១ កំណើតសត្វតិរច្ឆាន ។ ២ ប្រេតវិស័យ ។ ៣ អសុរកាយដែលមានមហិទ្ធិឫទ្ធិដ៏ច្រើនក្លៀវ
ក្លាសុំនួងជាដើម ។ ៤ លោកដែលគ្មានសេចក្តីចំរើនមានប្រការច្រើន មានអវីចីនរកជាដើម ។
៥ សង្រ្គោះយកគតិរបស់មនុស្សក្លូលផង ។ ៦ ចំពោះយកឋានៃទេវតាតែម្យ៉ាង ។

សុវណ្ណោ ទុព្ភណ្ណោ សុគតោ ទុគ្គតោ យថាកម្មូបគេ
សត្តេ បជានាមិ ។ អយំ ខោ មេ ព្រាហ្មណ ឥត្ថិយា
មជ្ឈេមេ យោមេ ទុតិយា វិជ្ជា អនិកតា អវិជ្ជា វិហតា
វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ
យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរ-
តោ ។ អយំ ខោ មេ ព្រាហ្មណ ទុតិយា អភិនិព្ពិទា
អហោសិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា ។
សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ
អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ
ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ
ចិត្តំ អភិនិន្នាមេសឹ សោ ឥទំ ទុក្ខន្តិ យថាភូតំ
អព្ភញ្ញាសឹ អយំ ទុក្ខសមុទយោតិ យថាភូតំ អព្ភញ្ញា-
សឹ អយំ ទុក្ខនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ
ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ

មានសណ្ឋានល្អនឹងអាក្រក់ ទៅកាន់សុគតិនឹងទុគ្គតិ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ រកែលែងជាឯចក្ខុរបស់មនុស្សសាមញ្ញ កំយើញច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ២ នេះឯងហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាកណ្តាលនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លាត់ចាត់ទៅ សេចក្តីចេះដឹងច្បាស់ក៏កើតឡើង ងងឹតខ្លាត់ចាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងប្រឹងស្មារតី មិនប្រហែសធ្វេស ទំប្រឹងវុតបំផ្លាញកិលេស មានចិត្តមូលស្តុងឥតមានទំនាដល់កាយនឹងជីវិតឡើយ ដូចជាបណ្ឌិតទាំងឡាយដែលបាននូវវិជ្ជាទី ២ ន៎ុះដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាវិជ្ជាទី ២ ដែលតថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ដែលញាស់ចេញចាកសម្បកពង ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផ្សុផង់ មិនមានកិលេសច្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងឆាប់មិនញាប់ញ័រ យ៉ាងនេះហើយ តថាគតទើបបង្អោនចិត្តចំពោះទៅកន្លាណជាហេតុឲ្យបានអស់ទៅនៃអាសវៈទាំងឡាយ គឺអាសវក្ខយញ្ញាណ តថាគតក៏ដឹងច្រាកដតាមពិតថា នេះជាទុក្ខ ដឹងច្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្រាកដតាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងច្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ

ឥមេ អាសវាតិ យេ ភិក្ខវេ អញ្ញាសិំ អយំ
អាសវសមុទយោតិ យេ ភិក្ខវេ អញ្ញាសិំ អយំ
អាសវនិរោធោតិ យេ ភិក្ខវេ អញ្ញាសិំ អយំ
អាសវនិរោធគាមិនី បដិបទាតិ យេ ភិក្ខវេ អញ្ញា-
សិំ តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ
កាមាសវាបិ ចិត្តំ វិមុច្চិត្ថ ភវាសវាបិ ចិត្តំ វិមុច្চិត្ថ(១)
អវិជ្ជាសវាបិ ចិត្តំ វិមុច្চិត្ថ វិមុត្តស្មឹ វិមុត្តមិតិ(២)
ញាណំ អហោសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ
កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អញ្ញាសិំ ។
អយំ ខោ មេ ព្រាហ្មណ បឋមេ យាមេ
តតិយា វិជ្ជា អជ្ជិតតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា
តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្ប-
មត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ អយំ
ខោ មេ ព្រាហ្មណ តតិយា អភិនិព្ពិទា អហោសិ
កុក្កុដបត្តបកសេវ្ហ អណ្ឌកោសម្ហាតិ ។

---

១ យោភុយ្យេន ជវោ បរំ ទិដ្ឋាសវាបីតិ អត្ថិ ។ ២ វិមុត្តម្ហីតិបិ ជាហេ ។

ដឹងច្បាស់តាមពិតថា ធម្មប៉ុណ្ណេះជាអាសវៈ ដឹងច្បាស់តាមពិតថា ធម្មនេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងច្បាស់តាមពិតថា នេះជាបដិបទាឲ្យដល់នូវសេចក្តីរលត់នៃអាសវៈ កាលដែលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តតថាគតក៏ផុតចាកកាមាសវៈ ចាកភវាសវៈ ចាកអវិជ្ជាសវៈ កាលបើចិត្តតថាគតបានរួចផុតស្រឡះហើយ ក៏ជ្រាបច្បាស់ដល់ឥតថាគតថា ចិត្តរួចផុតស្រឡះចាកអាសវៈហើយ ទាំងតថាគតក៏ដឹងច្បាស់ថា កំណើតរបស់អញអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អញក៏បានធ្វើស្រេចហើយ កិច្ចដទៃដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលព្រាហ្មណ៍វិជ្ជាទី ៣ នេះហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាបំផុតនៃរាត្រី លុះដល់សេចក្តីលង់ភ្លេចភ្លាត់បាត់ទៅ សេចក្តីចេះដឹងក៏កើតឡើង ដ៏ងឹតភ្លាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងអង្គុយប្រឹងស្មារតីមិនប្រហែសធ្វេស ទំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្មុងឥតមានទឹកនាដល់កាយទើងជីវិតឡើយ ដូចជាបណ្ឌិតទាំងឡាយ ដែលបានឮវិជ្ជាទី ៣ នុ៎ះដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍ ការត្រាស់ដឹងរបស់តថាគតជាគំរប់ ៣ នេះ ដូចគ្នានឹងការញាស់ចេញរបស់កូនមាន់អំពីសម្បកពង ។

[๔] ឯវំ វុត្តេ វេរញ្ជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច ដេដ្ឋោ ភវំ គោតមោ សេដ្ឋោ ភវំ គោតមោ អភិញ្ញតំ ភោ គោតម អភិញ្ញតំ ភោ គោតម សេយ្យថាបិ ភោ គោតម ឯកច្ចិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ(๑) ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ អធិវាសេតុ ច មេ ភវំ គោតមោ វេរញ្ជាយំ វស្សាវាសំ សង្ឃេ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។

---

๑ សព្ពត្ថ ឯវមេវាតិ បាឋោ ទិស្សតិ ។

[៤] កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេរញ្ជព្រាហ្មណ៍ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគវិញថា ព្រះគោតមដ៏ចំរើន ព្រះអង្គជាចម្បងជាងមនុស្ស ប្រសើរបំផុតជាងមនុស្ស បពិត្រព្រះគោតមដ៏ចំរើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ក្តីច្បាស់ណាស់) គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជាមនុស្សកាន់ប្រទីបត្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សមានភ្នែកវែមងមើលឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនោះសូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចំរើនជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណាគមន៍ស្មើដោយជីវិត មិនតែប៉ុណ្ណោះទេ សូមព្រះគោតមដ៏ចំរើន ទទួលនិមន្តន៍ចាំវស្សាជិតស្រុកវេរញ្ជាមួយអន្ទើដោយភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគក៏ព្រមទទួលនិមន្តដោយតុណ្ហីភាព (១) ។

---

១ ទទួលនិមន្តដោយស្ងៀម ។

อเนเกหิ เวเนยฺยนิกาเยหิ ปริวุตสฺส อตฺถสนฺทสฺสนวิธิกฺกมา ธมฺมาภิสมยา ปกาสิตา ปญฺญตฺตา ฐปิตา ปติฏฺฐาปิตา วิวฏา วิภตฺตา อุตฺตานีกตา ปกาสิตา ๆ

(๕) เตน โข ปน สมเยน เวเนยฺยา ปุพฺพณฺหสมยนฺติ ทุติยิกาติกา เสตฏฺฐิกา สลากภตฺตา น สุกรา ปุเพฺพน ปตฺตปูรา ยาเปตุนฺ ๆ เตน โข ปน สมเยน ปุพฺพภตฺตกา อสฺสภณฺฑิกา ปญฺหเมหิ อสฺสสเตหิ เวเนยฺยานนฺติ วิสฺสชฺชิตสฺส อุปคตา โหนฺติ ๆ เตหิ อสฺสมณฺฑลิกาสุ ภิกฺขูสุ ปตฺตปตฺตปูลกานิ[๑] ปญฺญตฺตานิ โหนฺติ ๆ ภิกฺขู ปุพฺพณฺหสมยนฺ ติ สิเตฺว ปตฺตจีวรมาทาย เวเนยฺยานนฺ[๒] ปิณฺฑาย ปวิสิตฺวา ปิณฺฑาย อลภมานา อสฺสมณฺฑลิกาสุ ปิณฺฑาย จริตฺวา ปตฺตปตฺตปูลกานิ อาทาย ปวิสิตฺวา

---

๑ สพฺพตฺถ ปตฺตปตฺตมูลกนฺติ ปาฬิ ทิสฺสติ ๆ ๒ ฉ. ช. เวเนยฺยานนฺ ๆ

លំដាប់នោះ វេរញ្ជព្រាហ្មណ៍ដ៏ឆ្លាស់ថា ព្រះអង្គទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះដ៏មានព្រះភាគហើយ ធ្វើប្រទក្សិណដើរចេញទៅ ។

(៥) សម័យនោះឯង ស្រុកវេរញ្ជាកើតអំណត់អត់ជាយ មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រៃក្រៃពេក មនុស្សណាដែលក្រលំបាកស្រាប់ក៏ស្លាប់ មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្សដែលមានទ្រព្យសម្បត្តិលុមទិញដូរស្រូវអង្ករគេបាន ក៏មិនដាយទិញដូរ បើលុះតែមានស្លាកកាន់ជាសំគាល់ទើបទិញដូរបាន ជនទាំងអស់ក្នុងស្រុកនោះព្យាយាមស្វែងរកអាហារបានដោយកម្រៃក្រៃពេក ។ សម័យនោះ មានពួកឈ្មួញសេះនៅក្នុងទត្តភាចប្រទេស នាំសេះចំនួន ៥០០ចូលមកនៅសម្រាកក្នុងស្រុកវេរញ្ជា កងរដូវខែវស្សា ។ ពួកឈ្មួញដែលនៅកងកេងសេះទាំងនោះ ក៏បានបញ្ជូតគ្នាឲ្យប្រគេនបាយគ្រឿមចំនួន ១ នាឡិ ។ ម្នាក់ ដល់ភិក្ខុទាំងឡាយ ។ លុះដល់ពេលបុព្វណ្ហសម័យ[1] ភិក្ខុទាំងឡាយស្លៀកស្បង់ទ្រង់ចីវរនឹងបាត្រ នាំគ្នាចូលទៅបិណ្ឌបាតក្នុងស្រុកវេរញ្ជា ក៏មិនប្រទះបានអាហារបិណ្ឌបាតសោះឡើយ ទើបទៅបិណ្ឌបាតខាងពួកឈ្មួញឯកេងសេះវិញ ក៏បានបាយគ្រឿម ១ នាឡិ ។ ម្នាក់ ហើយវិលមកកាមម

---

១ សម័យដាច់ពីណេភកខាងដើមនៃថ្ងៃ គឺពេលព្រឹកព្រលឹម ។

ទុទ្ទក្ខលេ តោដ្ដេត្វា តោដ្ដេត្វា បរិភុញ្ជន្តំ ។ អាយស្មា បជាឧដ្ឋោ បត្តប្ផលកំ សិលាយំ បិំសិត្វា(๑) ភគវតោ ឧបជាមេតិ ។ តំ ភគវា បរិភុញ្ជតិ ។ អស្សុសិ ខោ ភគវា ទុទ្ទក្ខលសទ្ទំ ។ ជានន្តាបិ តថាគតា បុច្ឆន្តិ ជានន្តាបិ ន បុច្ឆន្តិ កាលំ វិទិត្វា បុច្ឆន្តិ កាលំ វិទិត្វា ន បុច្ឆន្តិ អត្ថសញ្ចិតំ តថាគតា បុច្ឆន្តិ ន៑ អនត្ថសញ្ចិតំ អនត្ថសញ្ចិតេ សេតុឃាតោ តថាគតានំ ។ ទ្វីហាការេហិ ពុទ្ធា ភគវន្តោ តំក្ខ បដិបុច្ឆន្តិ ធម្មំ វា ទេសេស្សាម សាវកានំ វា សិក្ខាបទំ បញ្ញាបេស្សាមាតិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ តេន្ហិ ខោ សោ អានន្ទ ទុទ្ទក្ខលសទ្ទោតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ បតិស្សុត្វា អាវេចេសិ ។

---

๑ ម. បិំសិត្វា ។

យកបាយក្រៀមនោះបុកក្នុងឆ្នាល់រួចនាំគ្នាធាន់ ។ ចំណែកខាងព្រះអានន្ទដ៏មានអាយុ យកបាយក្រៀម ១ នាឡិ កំនកឆ្នាល់ថ្វាយហើយយកទៅថ្វាយព្រះដ៏មានព្រះភាគ ។ ព្រះអង្គក៏ទ្រង់ទទួលសោយបាយក្រៀមនោះ ។ វេលានោះ ព្រះសម្ពុទ្ធទ្រង់បានត្មៃសូរត្បាល់នឹងអង្រែនោះដែរ ។ ព្រះតថាគតតាំងឡាយ បានជ្រាបនូវហេតុហើយសួរក៏មាន បានជ្រាបហើយមិនសួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយសួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយមិនសួរក៏មាន ឯព្រះតថាគតតាំងឡាយ ព្រះអង្គតែងសួរនូវការណាដែលប្រកបដោយប្រយោជន៍ តម្កល់ដែលមិនប្រកបដោយប្រយោជន៍ ព្រះអង្គមិនសួរឡើយ ព្រោះព្រះតថាគតតាំងឡាយ ទ្រង់បានផ្តាច់បង់នូវតម្កល់មិនប្រកបដោយប្រយោជន៍តាំងឡាយ ដោយអរិយមគ្គដ៏ស្រឡះហើយ ។ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគតាំងឡាយ ទ្រង់តែងសួរនូវកិច្ចតាំងឡាយ ដោយហេតុពីរប្រការ គឺ ទ្រង់សួរដើម្បីនឹងសំដែងនូវធម៌ ១ ដើម្បីនឹងបញ្ញត្តនូវសិក្ខាបទដល់សាវកតាំងឡាយ ១ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ហៅព្រះអានន្ទដ៏មានអាយុមក ហើយទ្រង់សួរថា ម្នាលអានន្ទ សូរសំឡេងនោះជាសូរត្បាល់អង្រែឬអ្វី ។ ទើបព្រះអានន្ទដ៏មានអាយុក្រាបទូលរឿងទុំ+ឲ្យព្រះដ៏មានព្រះភាគជ្រាបគ្រប់ប្រការ ។

สาธุ สาธุ อานนฺท ตุเยฺหปิ อานนฺท สปฺปุริสเสวิ
วิตกฺโก ปณฺฑิโต ๘๓ สาลิมฺหสาธนโต อติมญฺญิสฺสตีติ ฯ

(๖) อถโข อายสฺมา มหาโมคฺคลฺลาโน เยน
ภควา เตนุปสงฺกมิ อุปสงฺกมิตฺวา ภควนฺตํ อภิวาเทตฺวา
เอกมนฺตํ นิสีทิ ฯ เอกมนฺตํ นิสินฺโน โข อายสฺมา
มหาโมคฺคลฺลาโน ภควนฺตเมว เอตทวโจ เอตมตฺถํ ภควโต
อาโรจยิ อุทปาทิ โข ภนฺเต เมตฺตา เจตโสวิมุตฺติ
อ สุภาย อุปฺปชฺเช นปฺปโหเม ยาเปตุ๋ สมฺมิสฺสา ภควา
มหาปปาโย เหตฺถิมตฺตานิ สมฺปฺปนฺนานิ[๑] เสยฺยถาปิ
อุทฺธคามนิ[๒] อนิลเสกา เอวมสฺสายํ สาตาปิ ภควา
ปปาตา ปริวตฺเตยฺย ตาทิสา ปปฺปชฺเชถาปิ ปริภุญฺชิสฺสตีติ ฯ

---

๑ ม. ภ. วสสมฺปนฺนา ฯ ๒ ฉ. อุทฺธมนิ ฯ

ព្រះអង្គត្រាស់សរសើរថា ត្រូវហើយ អានន្ទ ប្រពៃហើយ អានន្ទ អ្នកឯងពាល់គ្នាជាសញ្ញាសឈ្មុះវិសេសហើយ បណ្តាជនខាងក្រោយគេនឹងនឹកចង់ឲ្យនូវចង្ក្រានដែលគេចំអិន ដោយអង្កាវស្រូវខ្លាយ ព្រមទាំងម្ហូបលាយដោយសាច់ដ៏ឆ្ងាញ់ពិសារ (ដល់អ្នកពាល់គ្នា) ។

(៦) គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់បានក្រាបថ្វាយបង្គំព្រះអង្គដោយគោរពរួចហើយក៏គង់ក្នុងទីដ៏សមគួរ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលស្នើសេចក្តីនេះចំពោះព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ឥឡូវនេះ ស្រុកវេរញ្ជាកើតអំណត់អត់ជាយមនុស្សទាំងឡាយទំនងចិញ្ចឹមជីវិតបានដោយកម្រៃក្រៃពេក មនុស្សណាដែលក្រលំបាកស្រាប់ក៏ស្គាប់មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្សដែលមានទ្រព្យសម្បត្តិលួមទិញដូរស្រូវអង្កាវគេបាន ក៏មិនងាយទំនងទិញដូរ បើលុះតែមានស្មាកកាន់ជាសំគាល់នោះទើបទិញដូរបាន ជនទាំងអស់ក្នុងស្រុកនោះ នឹងព្យាយាមស្វែងរកអាហារបានដោយកម្រៃក្រៃពេក សូមទ្រង់ព្រះមេត្តាប្រោស ផ្នែកខាងក្រោមនៃផែនដីនេះ មានរសជាតិផ្អែមដូចទឹកឃ្មុំ ដែលស្អាតបរិសុទ្ធឥតលាយច្រឡំដោយមេឃ្មុំ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គចង់ប្រែត្រឡប់ផែនដីនេះឲ្យដូរឡើង ដើម្បីនឹងឲ្យកុំទាំងឡាយទាន់នូវរសជាតិ ដែលកើតឡើងអំពីស្រទាប់នៃផែនដីនោះ ។

យេ បន តេ មោក្ខលាភេន បហីនវិសវិតា ថាណា តេ
កេចិ ភវិស្សតីតំ ។ ឯតាហំ ភន្តេ ថាណឺ អភិ-
ដិម្ហិដិស្សាមិ សេយ្យថាបិ បមាបហីរ យេ បហីរ-
ដិសវិតា ថាណា តេ ឥទ្ធ សង្ការមេស្សាមិ ឯតេន
ហាត្តេន បហីរ បរិវត្តេស្សាមីតិ ។ អលំ មោក្ខលាភេ
ហ តេ រុច្ចិ បហីរ បរិវត្តេតុំ វិមលាសំបិ
សត្តា បដិលភេយ្យុន្តិ ។ សាធុ ភន្តេ សង្ឃោ
ភិក្ខុសង្ឃោ ទុត្តរកុរុំ បិណ្ឌាយ គច្ឆេយ្យាតិ ។
យេ បន តេ មោក្ខលាភេ ភិក្ខូ អដិដ្ឋិមត្តោ តេ តេ
ភវិស្សតីតិ ។ តថាហំ ភន្តេ ភវិស្សាមិ យថា សព្ពេ
ភិក្ខូ ភដ្ឋំស្សន្តីតិ ។ អលំ មោក្ខលាភេ ហ តេ រុច្ចិ
សព្ពេស្ស ភិក្ខុសង្ឃស្ស ទុត្តរកុរុំ បិណ្ឌាយ ភមនន្តិ ។

ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ចុះអ្នកនឹងយកមនុស្ស សត្វទាំងឡាយដែលនៅអាស្រ័យលើផែនដីនេះ ឲ្យទៅនៅឯណា ។ ព្រះមហាមោគ្គល្លានទូលតបថា សូមទ្រង់ព្រះមេត្តាត្រាស ខ្ញុំព្រះអង្គនឹងនិម្មិតបាតដៃម្ខាង ឲ្យបានដូចជាផែនដីធំ នឹងឲ្យសត្វទាំងឡាយដែលនៅអាស្រ័យលើផែនដី មកនៅលើបាតដៃម្ខាងនោះ ហើយខ្ញុំព្រះអង្គនឹងបែទូរផែនដីដោយដៃម្ខាង ។ ព្រះអង្គទ្រង់ឃាត់ថា មោគ្គល្លាន អ្នកកុំពេញចិត្តនឹងត្រឡប់ផែនដីនោះឡើយ សត្វទាំងឡាយនឹងបានទទួលសេចក្តីជ្រួលជ្រើមរចល់ ។ ព្រះមហាមោគ្គល្លានក្រាបទូលថា សូមទ្រង់ព្រះមេត្តាត្រាស ព្រះពុទ្ធដីកាដែលទ្រង់ត្រាស់មកនោះប្រែពៃហើយ (បើដូច្នោះ) សូមឲ្យភិក្ខុសង្ឃទាំងអស់ទៅបិណ្ឌបាតឯខត្តក្បែរទ្វីបវិញ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលមោគ្គល្លាន ចុះភិក្ខុទាំងឡាយឯណាដែលមិនមានឫទ្ធិ អ្នកនឹងធ្វើនូវភិក្ខុទាំងនោះដូចម្តេចទៅ ។ ព្រះមហាមោគ្គល្លានក្រាបទូលថា សូមទ្រង់ព្រះមេត្តាត្រាស ភិក្ខុទាំងអស់នឹងទៅបានយ៉ាងណា ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា កុំ មោគ្គល្លាន អ្នកកុំពេញចិត្តឲ្យភិក្ខុសង្ឃទាំងអស់ទៅបិណ្ឌបាតឯខត្តក្បែរទ្វីបនោះឡើយ ។

(๗) អថខោ អាយស្មតោ សារីបុត្តស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កតមេសានំ ខោ ពុទ្ធានំ ភគវន្តានំ ព្រហ្មចរិយំ ន ចិរដ្ឋិតិកំ អហោសិ កតមេសានំ ពុទ្ធានំ ភគវន្តានំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ អហោសីតិ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ៨ ខ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កតមេសានំ ខោ ពុទ្ធានំ ភគវន្តានំ ព្រហ្មចរិយំ ន ចិរដ្ឋិតិកំ អហោសិ កតមេសានំ ពុទ្ធានំ ភគវន្តានំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ អហោសីតិ ។ ភគវតោ ច សារីបុត្ត វិមុត្តិញ្ញ ភគវតោ ច សិទ្ធិញ្ញ

(ក) គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ លោកចូលទៅទៅកាន់ព្រះវិហារដ៏ជាទីចេញចាកពួក ហើយសម្ងំនៅក្នុងកម្មដ្ឋាន បានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រហ្មចរិយធម៌(១) របស់ព្រះពុទ្ធដ៏មានភាគចំណែកឆ្ងាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌មិនតាំងនៅយូរ ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានភាគចំណែកឆ្ងាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌តាំងនៅយូរ ។ គ្រានោះ ព្រះសារីបុត្តត្ថេរដ៏មានអាយុ ចេញចាកទីសម្ងំក្នុងកាលវេលាសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់បានក្រាបថ្វាយបង្គំព្រះអង្គដោយគោរព ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសួរចំពោះព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គចូលទៅនៅក្នុងវិហារជាទីចេញចាកពួក ហើយសម្ងំនៅក្នុងកម្មដ្ឋាន មានសេចក្តីត្រិះរិះថា ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានភាគចំណែកឆ្ងាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌មិនតាំងនៅយូរ ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានភាគចំណែកឆ្ងាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌តាំងនៅយូរ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ១ ព្រះដ៏មានព្រះភាគព្រះនាមសិខី ១

---

១ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ចំពោះត្រង់ព្រៃសិក្ខា គឺ សីល សមាធិ បញ្ញា ។

ភគវតោ ច វេស្សភុស្ស ព្រហ្មចរិយំ ន ចិរដ្ឋិតិកំ អហោសិ ភគវតោ ច សារីបុត្ត ភកុសន្ធស្ស ភគវតោ ច កោនាគមនស្ស ភគវតោ ច កស្សបស្ស ព្រហ្ម-
ចរិយំ ចិរដ្ឋិតិកំ អហោសីតិ ។ តោ ន្វ ខោ ភន្តេ
ហេតុ តោ បច្ចយោ យេន ភគវតោ ច វិបស្សិស្ស
ភគវតោ ច សិខិស្ស ភគវតោ ច វេស្សភុស្ស
ព្រហ្មចរិយំ ន ចិរដ្ឋិតិកំ អហោសីតិ ។ ភគវ ច
សារីបុត្ត វិបស្សី ភគវ ច សិខី ភគវ ច វេស្សភូ
កិលាសុជោ អហោសុំ សាវកានំ វិត្ថារេន ធម្មំ
ទេស្សេតុំ អប្បកញ្ច នេសំ អហោសិ សុត្តំ គេយ្យំ
វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ
អព្ភូតធម្មំ វេទល្លំ អប្បញ្ញត្តំ សាវកានំ សិក្ខាបទំ
អនុន្ទិដ្ឋំ ថាតិមោក្ខំ តេសំ ពុទ្ធានំ ភគវន្តានំ អន្តលាន

ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ ១ ជាព្រហ្មចរិយធម៌មិនបឹតនៅយូរ ម្នាលសារីបុត្ត ឯព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមកកុសន្ធ ១ ព្រះដ៏មានព្រះភាគព្រះនាមកោនាគមន ១ ព្រះដ៏មានព្រះភាគព្រះនាមកស្សប ១ ជាព្រហ្មចរិយធម៌បឹតនៅបានយូរ ។ ព្រះសារីបុត្តត្ថេរក្រាបទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគ ព្រះនាមវិបស្សី ១ ព្រះដ៏មានព្រះភាគព្រះនាមសិខី ១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ ១ បានជាមិនបឹតនៅយូរ នោះតើព្រោះហេតុនឹងបច្ច័យដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ១ ព្រះដ៏មានព្រះភាគព្រះនាមសិខី ១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ ១ ព្រះអង្គមិនសូវប្រឹងប្រែង[1]សំដែងធម៌ដល់សាវកទាំងឡាយដោយពិស្តារប៉ុន្មានទេ ព្រហ្មចរិយធម៌មានអង្គ ៩ ប្រការ របស់ព្រះពុទ្ធទាំងឡាយនោះគឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ជាធម៌មានចំនួនតិច ។ ណាស់ សិក្ខាបទក៏ព្រះពុទ្ធទាំងនោះមិនបានបញ្ញត្តដល់សាវកទាំងឡាយទេ អាណាបាតិមោក្ខ ក៏ព្រះពុទ្ធទាំងនោះមិនបានសំដែងទៀយ ដល់អំណើះ ឥតពីព្រះពុទ្ធដ៏មានជោគ

---

